ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ០៥នាក់
## និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

- **អ្នកព្យាបាលជាសះស្បើយ** បានកើនដល់ចំនួន **១០៣នាក់** (ស្មើនឹង ៨៤,៤៣% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ២៥នាក់ និងបុរស ៧៨នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្ត្រីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៧នាក់ (ក្នុងនេះ មានទារកអាយុ ០៩ខែ) ស្ត្រីជនជាតិបារាំង ២០នាក់ បុរសជនជាតិកាណាដា ០១នាក់ បុរសជនជាតិម៉ាឡេស៊ី១២នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ បុរសជនជាតិខ្មែរ ៣៧នាក់ និងស្ត្រីជនជាតិខ្មែរ ០៥នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។
- **អ្នកដែលកំពុងសម្រាកព្យាបាល** បានថយចុះ សរុបនៅសល់ចំនួន **១៩នាក់** (ស្ត្រី ០៩នាក់ និង បុរស ១០នាក់)នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១២២នាក់** (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។

**២. ករណីជាសះស្បើយ៖** ចំនួន ០៥នាក់

- ជនបរទេស ០៣នាក់ (ជនជាតិអាមេរិកកាំង ០២នាក់ (បុរសអាយុ ៥៩ឆ្នាំ ជាស្វាមី ស្ត្រីអាយុ ៦២ឆ្នាំ ជាភរិយា) និង បុរសជនជាតិអង់គ្លេសអាយុ ៦១ឆ្នាំ) ដែលជាភ្ញៀវទេសចរធ្វើដំណើរតាមនាវា Viking Cruise Journey បានចូលស៊ំចតនៅខេត្តកំពង់ចាមកន្លងមក ត្រូវបានបញ្ជូនពីមន្ទីរពេទ្យខេត្តកំពង់ចាមមកសម្រាកព្យាបាលនៅមន្ទីរពេទ្យមួយក្នុងរាជធានីភ្នំពេញ បច្ចុប្បន្នបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតអោយចេញពីមន្ទីរពេទ្យ ហើយបុគ្គលជនជាតិអាមេរិកកាំង ០២នាក់ និងជនជាតិអង់គ្លេសម្នាក់ខាងលើនេះ បានវិលត្រឡប់ទៅប្រទេសអាមេរិក និងទៅប្រទេសអង់គ្លេសវិញហើយ កាលពីយប់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បុរសជនជាតិកាណាដាអាយុ ៥៥ឆ្នាំ បម្រើការនៅសាលាអន្តរជាតិមួយនៅកោះពេជ្រ ស្នាក់នៅក្នុងបុរីមួយនៅកោះពេជ្រ បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២ លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យនៅរាជធានីភ្នំពេញ។

- បុរសជនជាតិខ្មែរអាយុ ៣៨ឆ្នាំ ដែលមានទីលំនៅភូមិពោធិ៍២ ឃុំតារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតអោយចេញពីមន្ទីរពេទ្យខេត្តបាត់ដំបង។

**៣. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា